# សង្ខេបសម្រាប់គោលនយោបាយ

CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ
សម្រាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

ឆ្នាំ ២០១១ លេខ ០៧


# កត្តាកំណត់ប្រពលវប្បកម្មកសិកម្មនៅកម្ពុជា៖ មុខងារនៃចំណាកស្រុក សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងឥណទាន[១]


*ដោយ តុង គឹមស៊ុន[២] ហែម សុចិត្ត[២] និង* Paulo SANTOS[៣]


## ខ្លឹមសារសំខាន់ៗ

- ការមានទឹកប្រើប្រាស់ និងដីកសិកម្ម ជាកត្តាសំខាន់សម្រាប់កំណត់លទ្ធភាពធ្វើស្រែពីរដងក្នុងមួយឆ្នាំ។
- ការធ្វើស្រែបានពីរដងក្នុងមួយឆ្នាំ និងចំណាកស្រុកមិនជាប់ទាក់ទងគ្នាខ្លាំងទេ។
- គ្រួសារពឹងផ្អែកលើកម្លាំងសត្វអូសទាញក្នុងផលិតកម្មកសិកម្ម មិនទំនងជាអាចធ្វើស្រែបានពីរដងក្នុងមួយឆ្នាំទេ។
- ប្រាក់កម្ចី និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មមិនមានផលប៉ះពាល់អ្វីច្រើនដល់ការធ្វើស្រែពីរដងក្នុងមួយឆ្នាំទេ។ ត្រូវមានការស្រាវជ្រាវបន្ថែម ដើម្បីស្វែងយល់ពីរឿងនេះ។

## បញ្ហាចោទ

ការកសាងប្រព័ន្ធធារាសាស្ត្រ ដែលទទួលមូលនិធិពីរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ដូចជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី កាន់តែទទួលបានអាទិភាពខ្ពស់ តាំងពីទសវត្សរ៍១៩៨០[៤] មក។ វិនិយោគលើប្រព័ន្ធធារាសាស្ត្រ បានកើនឡើងដោយសាររដ្ឋាភិបាល បានទទួលស្គាល់ពីសារៈសំខាន់នៃការគ្រប់គ្រងទឹក ដើម្បីលើកកម្ពស់ផលិតកម្មស្រូវនៅកម្ពុជា។ ក្នុងឆ្នាំ២០០៤ រដ្ឋាភិបាលបានអនុម័តឡើងនូវយុទ្ធសាស្ត្រចតុកោណ ទុកជាឯកសារគោលសម្រាប់ណែនាំដល់ការធ្វើផែនការអភិវឌ្ឍន៍ជាតិ។ ខ្លឹមសារសំខាន់នៃយុទ្ធសាស្ត្រនេះ គឺ ការលើកកម្ពស់ផលិតកម្មកសិកម្មដោយផ្តោតជាពិសេសលើការពង្រីកផ្ទៃដីស្រោចស្រព ក្នុងការរំពឹងថា ប្រព័ន្ធស្រោចស្រពធ្វើឲ្យកសិករមិនសូវពឹងផ្អែកលើទឹកភ្លៀង អាចធ្វើការដាំដុះបានកាន់តែច្រើន និងកាន់តែប្រាកដប្រជា ហើយទទួលបានផលិតភាពកាន់តែខ្ពស់ និងមានជីវភាពកាន់តែប្រសើរ។

គួរកត់សម្គាល់ថា ប្រព័ន្ធធារាសាស្ត្រតែម្យ៉ាងមិនអាចបង្កើនផលិតកម្មកសិកម្មដោយស្វ័យប្រវត្តិនោះទេ។ ការសិក្សារួមគ្នាមួយរវាង វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) សាកលវិទ្យាល័យស៊ីដនី (USYD) ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ដែលត្រូវមានការវាយតម្លៃខាងសង្គម លើគម្រោងធារាសាស្ត្រក្នុងខេត្ត៦ជុំវិញបឹងទន្លេសាប បានបង្ហាញថា កសិករមិនបានធ្វើស្រែប្រាំងទេ ដោយសារកត្តាដូចជា៖ (១) ប្រព័ន្ធធារាសាស្ត្រច្រើនមានទីតាំងនៅតំបន់ទំនាប (២) ចំណាយ

---

១ អត្ថបទសង្ខេបគោលនយោបាយនេះ ផ្អែកលើឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI ចងក្រងដោយ តុង-គឹមស៊ុន ហែម-សុចិត្ត និង Paulo SANTOS (ចេញផ្សាយក្នុងពេលខាងមុខ) មានចំណងជើងថា កត្តាកំណត់ប្រពលវប្បកម្មកសិកម្មនៅកម្ពុជា៖ មុខងារនៃចំណាកស្រុកចេញ សេវាកម្មផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងកំហិតផ្នែកឥណទាន។ ឯកសារពិភាក្សានេះ បង្ហាញលទ្ធផលស្រាវជ្រាវក្នុងសមាសភាគសេដ្ឋកិច្ចនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (WRMRCDP) ដែលជាគម្រោងរយៈពេល ៥ឆ្នាំ ទទួលបានមូលនិធិពី AusAID និងសំដៅលើកកម្ពស់ការប្រើប្រាស់ និងអភិបាលកិច្ចធនធានទឹក ដើម្បីបង្កើនផលិតកម្មកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពនៅកម្ពុជា។

២ កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI

៣ មហាវិទ្យាល័យកសិកម្ម ស្បៀងអាហារ និងធនធានធម្មជាតិ នៃសាកលវិទ្យាល័យស៊ីដនី

៤ សម្រាប់បញ្ជីលម្អិតអំពីម្ចាស់ជំនួយ សូមមើលឯកសារ Nang *et al.* (ចេញផ្សាយក្នុងពេលខាងមុខ)។

ខ្ពស់ក្នុងការបូមទឹកពីប្រឡាយមេចូលទៅស្រែ (៣) ស្រូវប្រាំងងាយរងការបំផ្លាញដោយសត្វល្អិត និង/ឬ សត្វចិញ្ចឹមដែលដើររកស៊ីគ្មានគេឃ្វាល និង (៤) ប្រព័ន្ធធារាសាស្ត្រមានទឹកមិនគ្រប់គ្រាន់ (CDRI 2010)។ ការសិក្សារកឃើញទៀតថា ប្រភេទដី (ឧ. ដីខ្សាច់មិនអាចផ្ទុកទឹកបានល្អទេ) គឺជាកត្តាមួយទៀតដែលជះឥទ្ធិពលដល់ចំណូលចិត្តធ្វើស្រូវប្រាំង (Ibid)។ ទោះយ៉ាងនេះក្តី ឥទ្ធិពលនៃចំណាកស្រុក ឥណទាន និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ទៅលើការសម្រេចចិត្តធ្វើស្រែពីរដងក្នុងមួយឆ្នាំមិនធ្លាប់បានធ្វើការសិក្សានៅកម្ពុជាទេ។ តួយ៉ាង ចំណាកស្រុក ប្រហែលជាបានកាត់បន្ថយចំនួនកម្លាំងពលកម្មសម្រាប់ផលិតកម្មកសិកម្ម ហើយអាចជាឧបសគ្គរាំងដល់ការធ្វើស្រែពីរដងក្នុងមួយឆ្នាំ។ ផ្ទុយទៅវិញ ការធ្វើស្រែពីរដងក្នុងមួយឆ្នាំ ទំនងមានផលប៉ះពាល់អវិជ្ជមានទៅលើចំណាកស្រុក ព្រោះវាធ្វើឲ្យសមាជិកគ្រួសារ មិនសូវត្រូវការធ្វើចំណាកស្រុកទៅកន្លែងផ្សេង ដើម្បីស្វែងរកការងារធ្វើនៅរដូវទំនេរនោះទេ។ អត្ថបទសង្ខេបគោលនយោបាយនេះ មានគោលបំណងបង្ហាញអំពី (១) ការជះឥទ្ធិពលទៅវិញទៅមករវាងការសម្រេចចិត្តធ្វើចំណាកស្រុក និងការធ្វើស្រែពីរដងក្នុងមួយឆ្នាំ និង (២) តួនាទីឥណទាន និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ក្នុងការសម្រេចចិត្តធ្វើប្រពលវប្បកម្មកសិកម្ម ឬការធ្វើស្រែពីរដងក្នុងមួយឆ្នាំ។

## ករណីសិក្សា

ឯកសារនេះ បង្ហាញលទ្ធផលសំខាន់ៗមួយចំនួននៃអង្កេតគ្រួសារធ្វើឡើងក្នុងឆ្នាំ២០០៨ និង ២០០៩ ដោយ CDRI នៅក្នុងប្រព័ន្ធធារាសាស្ត្រចំនួន ១០កន្លែង នៅ ៣ ខេត្ត (កំពង់ឆ្នាំង កំពង់ធំ និងពោធិ៍សាត់) ក្នុងតំបន់អាងទន្លេសាប។ ពីក្នុងប្រព័ន្ធធារាសាស្ត្រនីមួយៗ ការសិក្សាបានជ្រើសយក ៣០គ្រួសារដោយចៃដន្យ (សរុប ៣០០ គ្រួសារ) សម្រាប់ការធ្វើសម្ភាសន៍ជាមូលដ្ឋាន ដើម្បីទទួលបានព័ត៌មានអំពី លក្ខណៈគ្រួសារ អាជីវកម្មរបស់គ្រួសារ លក្ខណៈដីកសិកម្មនិងលំនៅស្ថាន សត្វចិញ្ចឹម និងទ្រព្យមូលធនផ្សេងៗទៀត។ នៅក្នុងអង្កេតតាមដានបន្តបន្ទាប់មាន ២៣៥គ្រួសារ ត្រូវបានសម្ភាសនៅរដូវវស្សាក្នុងអំឡុងឆ្នាំ២០០៨ និង ២០០៩ និង ២២០គ្រួសារត្រូវបានសម្ភាសនៅរដូវប្រាំងក្នុងអំឡុងឆ្នាំ២០០៨ និង ២០០៩។ ដោយសារគ្រួសារធ្វើស្រែពីរដងក្នុងមួយឆ្នាំ ត្រូវបានកំណត់ថាជាគ្រួសារដែលធ្វើទាំងស្រែវស្សា និងស្រែប្រាំងលើក្បាលដីតែមួយ[៥] ដូច្នេះ ទិន្នន័យនៅរដូវវស្សា និងរដូវប្រាំង ក្នុងឆ្នាំនីមួយៗត្រូវបានបញ្ចូលគ្នា ដែលនាំឲ្យចំនួនគ្រួសារសរុបថយចុះមកត្រឹម ២៣៣គ្រួសារក្នុងមួយឆ្នាំ។

## លទ្ធផលស្រាវជ្រាវសំខាន់ៗ

ការវិភាគទិន្នន័យអង្កេតគ្រួសារទាំង ២ជុំ បង្ហាញថា គ្រួសារ ១៤% បានធ្វើស្រែពីរដងក្នុងមួយឆ្នាំ នៅឆ្នាំ២០០៨ និង ១៧% នៅឆ្នាំ២០០៩។ មានគ្រួសារត្រឹមតែ ៩-១០% ប៉ុណ្ណោះ ដែលទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅក្នុងឆ្នាំអង្កេតនីមួយៗ។ សត្វអូសទាញសម្រាប់ភ្ជួររាស់ មានជាមធ្យម ១,៧៥ក្បាល/គ្រួសារក្នុងឆ្នាំ២០០៨ ហើយបានធ្លាក់ចុះគួរឲ្យកត់សម្គាល់មកត្រឹម ១,២៨ក្បាល/គ្រួសារក្នុងឆ្នាំ២០០៩។ ផ្ទុយទៅវិញ សន្ទស្សន៍បរិក្ខារកសិកម្មជាមធ្យម[៦] កើនពី ០,០១ ក្នុងឆ្នាំ២០០៨ ដល់ ០,០៧ ក្នុងឆ្នាំ២០០៩ ដែលបញ្ជាក់ថា គ្រួសារនៅជនបទបានទទួលយករបៀបធ្វើកសិកម្មតាមបែបទំនើបកាន់តែច្រើនឡើង។ សមាមាត្រនៃគ្រួសារជំពាក់បំណុលគេ បានកើនពី ៣២% ក្នុងឆ្នាំ២០០៨ ដល់ ៤០% ក្នុងឆ្នាំ២០០៩។ គ្រួសារក្នុងខេត្តពោធិ៍សាត់ប្រមាណ ៣៨% បានធ្វើស្រែពីរដងក្នុងមួយឆ្នាំ សម្រាប់រយៈពេលដែលបានធ្វើអង្កេតទាំងពីរឆ្នាំ។ នៅខេត្តកំពង់ធំ គ្រួសារធ្វើស្រែពីរដងក្នុងមួយឆ្នាំមាន ១៣%ក្នុងឆ្នាំ២០០៩ ឬកើនឡើង ៤ឯកតាភាគរយ ធៀបនឹងឆ្នាំ២០០៨។ នៅឆ្នាំ២០០៨ ក្នុងខេត្តកំពង់ឆ្នាំង គ្មានគ្រួសារណាមួយបានធ្វើស្រែពីរដងក្នុងមួយឆ្នាំទេ ហើយនៅឆ្នាំ២០០៩ មានគ្រួសារត្រឹមតែ ៤% ប៉ុណ្ណោះដែលបានធ្វើស្រែពីរដងក្នុងមួយឆ្នាំ។ នៅឆ្នាំ២០០៨ គ្រួសារនៅខេត្តពោធិ៍សាត់ប្រហែល ២៨% មានសមាជិកធ្វើចំណាកស្រុក[៧] ធៀបនឹង ១៨% នៅខេត្តកំពង់ឆ្នាំង និង ១០% នៅខេត្តកំពង់ធំ។ ប៉ុន្តែក្នុងឆ្នាំ២០០៩ គ្រួសារមានសមាជិកធ្វើចំណាកស្រុកមាន ២៤% នៅខេត្តកំពង់ឆ្នាំង ១៣% នៅខេត្តពោធិ៍សាត់ និង ១២% នៅខេត្តកំពង់ធំ។

ដូចបានបង្ហាញក្នុងក្រាហ្វិក ១ សមាមាត្រគ្រួសារ នៅខេត្តពោធិ៍សាត់ ដែលបានធ្វើស្រែពីរដងនៅឆ្នាំ២០០៨ មានកម្រិតខ្ពស់ជាងសមាមាត្រនៅខេត្តកំពង់ធំ និងកំពង់ឆ្នាំង។ ក្នុងឆ្នាំដដែល ចំណែកនៃគ្រួសារមាន

---

៥ និយមន័យនេះ បានកំណត់តាមរយៈការពិភាក្សាជាមួយកសិករ សមាជិកសហគមន៍កសិករប្រើប្រាស់ទឹក និងដៃគូក្នុងតំបន់ផ្សេងទៀតនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្តចំនួន ៣ ធ្វើឡើងក្នុងខេត្តកំពង់ធំ កំពង់ឆ្នាំង និងពោធិ៍សាត់។

៦ សន្ទស្សន៍បរិក្ខារកសិកម្មត្រូវបានប៉ាន់ស្មាន ដោយប្រើវិធីសាស្ត្រ Principal Component Analysis។

៧ ចំណាកស្រុក ត្រូវបានកំណត់ថា យ៉ាងហោចណាស់មានសមាជិកគ្រួសារមួយរូប បាត់មុខពីក្នុងគ្រួសារ ក្នុងរយៈពេលលើសពី ២ខែជាប់គ្នា។

ក្រាហ្វិក ១. ការធ្វើស្រែពីរដងក្នុងមួយឆ្នាំ និងចំណាកស្រុក ឆ្នាំ២០០៨-២០០៩




ប្រភព៖ ទិន្នន័យអង្កេតរបស់វិទ្យាស្ថាន CDRI (២០០៨-២០០៩)

សមាជិកធ្វើចំណាកស្រុកក្នុងខេត្តពោធិ៍សាត់ ក៏មានកម្រិតខ្ពស់ជាងខេត្តទាំងពីរទៀតដែរ។ ក្នុងឆ្នាំ២០០៩ សមាមាត្រគ្រួសារ ដែលបានធ្វើស្រែពីរដងក្នុងមួយឆ្នាំនៅខេត្តពោធិ៍សាត់ មានប្រហាក់ប្រហែលគ្នានឹងឆ្នាំ២០០៨ ទោះបីជាចំនួនគ្រួសារធ្វើចំណាកស្រុកនៅក្នុងខេត្តនេះ បានធ្លាក់ចុះគួរឲ្យកត់សម្គាល់ក្តី។ នៅខេត្តកំពង់ឆ្នាំងវិញ ទាំងគ្រួសារដែលធ្វើស្រែពីរដងក្នុងមួយឆ្នាំ និងគ្រួសារមានសមាជិកធ្វើចំណាកស្រុក សុទ្ធតែមានសមាមាត្រកើនឡើងក្នុងឆ្នាំ២០០៩ ធៀបនឹងឆ្នាំ២០០៨។ ចំណុចនេះបង្ហាញថា ការធ្វើស្រែពីរដងក្នុងមួយឆ្នាំ និងចំណាកស្រុកទំនងមិនមានទំនាក់ទំនងគ្នាច្រើនទេ ហើយកត្តាកំណត់នៃការធ្វើស្រែពីរដងក្នុងមួយឆ្នាំ ប្រហែលមិនមែនសុទ្ធតែទាក់ទងនឹងចំនួនជនចំណាកស្រុកនោះទេ។ រឿងនេះ អាចដោយសារតែកម្លាំងពលកម្មនៅជនបទកម្ពុជា ភាគច្រើនមិនមានការងារធ្វើគ្រប់គ្រាន់។

ក្រៅពីការពិនិត្យអំពីទំនាក់ទំនងរវាងការធ្វើស្រែពីរដងក្នុងមួយឆ្នាំ និង ចំណាកស្រុក ការសិក្សាក៏បានព្យាយាមកំណត់នូវកត្តាផ្សេងៗ ដែលជាឧបសគ្គចំពោះកសិករក្នុងការធ្វើស្រែពីរដងក្នុងមួយឆ្នាំ លើក្បាលដីតែមួយផងដែរ។ បរិក្ខារកសិកម្ម សត្វអូសទាញសម្រាប់ការភ្ជួររាស់ និងប្រាក់កម្ចី ស្ថិតក្នុងចំណោមអថេរសំខាន់ៗដែលមានឥទ្ធិពលលើការអនុវត្តធ្វើស្រែពីរដងក្នុងមួយឆ្នាំ។ គ្រួសារធ្វើស្រែពីរដងក្នុងមួយឆ្នាំ មានបរិក្ខារកសិកម្ម ច្រើនជាងគ្រួសារធ្វើស្រែតែមួយដងក្នុងមួយឆ្នាំ (តារាង ១)។ ដំណាលគ្នានេះ អត្រាគ្រួសារធ្វើស្រែពីរដងក្នុងមួយឆ្នាំដែលមានប្រើប្រាស់ប្រាក់កម្ចី ក៏មានកម្រិតខ្ពស់ជាងគ្រួសារធ្វើស្រែតែមួយដងក្នុងមួយឆ្នាំដែរ។ ភាពខុសគ្នានៃអថេរទាំងពីរនេះ មានភាពជាក់លាក់ពីខេត្តមួយទៅខេត្តមួយ។ ចំណុចនេះបង្ហាញថា សន្ទស្សន៍បរិក្ខារកសិកម្ម សត្វអូសទាញសម្រាប់ភ្ជួររាស់ និងលទ្ធភាពទទួលបានឥណទាន អាចជាសូចនាករដ៏សំខាន់សម្រាប់កំណត់លើការធ្វើស្រែពីរដងក្នុងមួយឆ្នាំ។ ផ្ទុយទៅវិញ ការធ្វើស្រែពីរដងក្នុងមួយឆ្នាំ ហាក់មិនទាក់ទងជាមួយនឹងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មទេ ដោយហេតុថាគ្រួសារធ្វើស្រែមួយដងក្នុងមួយឆ្នាំ ទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ច្រើនជាងគ្រួសារធ្វើស្រែពីរដងក្នុងមួយឆ្នាំទៀតផង។

ដោយរក្សាកត្តាផ្សេងទៀតឲ្យនៅថេរ និងដោយគិតបញ្ចូលនូវទំនាក់ទំនងរវាង ការសម្រេចចិត្តធ្វើស្រែពីរដង

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

តារាង ១. អថេរសំខាន់ៗដែលកំណត់លើការធ្វើស្រែពីរដងក្នុងមួយឆ្នាំ (មធ្យម)

| អថេរ | ២០០៨ | | ២០០៩ | |
|---|---|---|---|---|
| | ការធ្វើស្រែមួយដង ក្នុងមួយឆ្នាំ | ការធ្វើស្រែពីរដង ក្នុងមួយឆ្នាំ | ការធ្វើស្រែមួយដង ក្នុងមួយឆ្នាំ | ការធ្វើស្រែពីរដង ក្នុងមួយឆ្នាំ |
| សន្ទស្សន៍បរិក្ខារកសិកម្ម | -0.19 | 1.25 | -0.07 | 0.83 |
| សត្វអូសទាញសម្រាប់ភ្ជួររាស់ | 1.89 | 0.84 | 1.34 | 1.03 |
| ជនចំណាកស្រុកចេញ (១= មាន) | 0.17 | 0.25 | 0.18 | 0.13 |
| ប្រាក់កម្ចី (១= មាន) | 0.29 | 0.50 | 0.38 | 0.51 |
| សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម (១= មាន) | 0.11 | 0.06 | 0.10 | 0.03 |

ប្រភព៖ ទិន្នន័យអង្កេតរបស់ CDRI (២០០៨-២០០៩)

ក្នុងមួយឆ្នាំ និងការសម្រេចចិត្តធ្វើចំណាកស្រុក គេអាចសន្និដ្ឋានបានថា៖

- ការធ្វើស្រែពីរដងក្នុងមួយឆ្នាំ និងការសម្រេចចិត្តធ្វើចំណាកស្រុក មិនមានទំនាក់ទំនងគ្នាជិតស្និទ្ធទេ។
- ការមានទឹកប្រើប្រាស់ និងដីកសិកម្ម ជាកត្តាដ៏សំខាន់សម្រាប់កំណត់លើការធ្វើស្រែពីរដងក្នុងមួយឆ្នាំ។
- គ្រួសារដែលពឹងផ្អែកលើកម្លាំងសត្វអូសទាញសម្រាប់ផលិតកម្មកសិកម្ម ទំនងជាមិនសូវបានធ្វើស្រែពីរដងក្នុងមួយឆ្នាំទេ។
- ប្រាក់កម្ចី និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម មិនមែនជាកត្តាជម្រុញដល់ ការធ្វើស្រែពីរដងក្នុងមួយឆ្នាំទេ។

## លទ្ធផលសម្រាប់គោលនយោបាយ

លទ្ធផលសំខាន់ៗសម្រាប់គោលនយោបាយ ដែលអាចទាញចេញពីការសិក្សា មានដូចតទៅ៖

- គោលនយោបាយសំដៅបង្កើនប្រព័ន្ធធារាសាស្ត្រ និងផ្តល់ដីសម្បទានសេដ្ឋកិច្ច-សង្គមកិច្ច នៅតំបន់ជនបទអាចដើរតួនាទីយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ផលិតកម្មកសិកម្ម។
- ការពង្រឹង និងពង្រីកសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ក៏ជាយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់បង្កើនផលិតភាពកសិកម្ម។

## ឯកសារយោង

Cambodia Development Resource Institute (2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges*, Working Paper Series No. 48 (Phnom Penh: CDRI)

Wokker, C., P. Santos & Ros B. (forthcoming), *Irrigation Water Productivity in Cambodian Rice Systems*, CDRI Working Paper (Phnom Penh: CDRI)

Nang P., Khiev D., I. Whitehead. & P. Hirsch (forthcoming), *Improving the Govenance of Water Resources in Cambodia: A Stakeholder Analysis*, CDRI Working Paper (Phnom Penh: CDRI)

Tong K., Hem S. and P. Santos (forthcoming), *What Limits Agricultural Intensification in Cambodia? The Role of Emigration, Agricultural Extension Services and Credit Constraints*, CDRI Working Paper (Phnom Penh: CDRI)